00270026

E5/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

| |
|---|
| **ឯកសារដើម** |
| ORIGINAL DOCUMENT/DOCUMENT ORIGINAL |
| ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / JAN / 2009 |
| ម៉ោង (Time/Heure): 10:30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy |

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/អជសដ
Case File/ Dossier N° 001/18-07-2007-ECCC/TC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម **និល ណុន** ប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ | ០៩ ខែ មករា ឆ្នាំ ២០០៩ |
| ចំណាត់ថ្នាក់ឯកសារ | សាធារណៈ: |

| |
|---|
| **ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម** |
| CERTIFIED COPY/COPIE CERTIFIÉE CONFORME |
| ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 09 / JAN / 2009 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy |

# របៀបវារៈ: សម្រាប់កិច្ចប្រជុំរៀបចំសវនាការ

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Robert PETIT

**<u>ជនជាប់ចោទ</u>**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

គង់ ពិសី

ហុង គីមសួន

យុង ផានិត

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Silke STUDZINSKY
Martine JACQUIN
Philippe CANONNE

ទី ស្រីនណា

**<u>មេធាវីជនជាប់ចោទ</u>**

ការ សាវុត្ថ

François ROUX

១. យោងសេចក្ដីជូនដំណឹងអំពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឱ្យភាគីដាក់ឯកសារបន្ថែម ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ និងតាមសំណើរបស់ភាគី[1]សុំដាក់នូវរបៀបវារៈបន្ថែម ខាងក្រោមនេះគឺជារបៀបវារៈស្ថាពរ សម្រាប់កិច្ចប្រជុំរៀបចំសវនាការ ដែលនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៥ និង ១៦ ខែ មករា ឆ្នាំ ២០០៩ នៅក្នុងសាលសវនាការធំរបស់ អ.វ.ត.ក

២. យោងតាមវិធាន ៧៩.៩ នៃវិធានផ្ទៃក្នុង កិច្ចប្រជុំនេះនឹងត្រូវធ្វើឡើងជាអសាធារណៈ ហើយព័ត៌មានដែលពិភាក្សានៅក្នុងកិច្ចប្រជុំនេះត្រូវចាត់ទុកជាការសម្ងាត់ លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយអង្គជំនុំជម្រះសាលាដំបូង ។

៣. ដោយសារតែចំណុចនីមួយៗនៅក្នុងរបៀបវារៈនេះទាក់ទងនិងផ្នែកបច្ចេកទេសនិងនីតិវិធី ជនជាប់ចោទមិនតម្រូវឱ្យចូលរួមក្នុងកិច្ចប្រជុំនេះទាំងមូល ឬផ្នែកណាមួយឡើយ ប្រសិនបើគាត់មិនចង់ចូលរួម ។

៤. ផ្នែកឬអង្គភាពនានារបស់ អ.វ.ត.ក តម្រូវឱ្យចូលរួមទៅតាមរបៀបវារៈដែលបានកំណត់ ពាក់ព័ន្ធទៅនិងសកម្មភាពការងាររបស់ខ្លួន ទន្ទឹមនឹងនេះគាត់ត្រូវមានវត្តមានជាប្រចាំសម្រាប់ផ្នែកនៃរបៀបវារៈដែលនៅសល់ផ្សេងទៀតដើម្បីផ្ដល់នូវព័ត៌មានណាមួយដែលចាំបាច់ ។ ផ្នែកឬអង្គភាពទាំងនេះក៏អាចចូលរួមផ្នែកនៃរបៀបវារៈផ្សេងទៀតផងដែរ ប្រសិនបើខ្លួនមានបំណងចង់ចូលរួម ។

៥. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាង នឹងត្រូវបានអនុញ្ញាតិឱ្យលើកឡើងនូវទស្សនៈរបស់ខ្លួនទៅតាមប្រធានបទនៃរបៀបវារៈ តាមរយៈមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ ប្រសិនបើមាន ។

៦. ដោយសារតែកន្លែងអង្គុយមានចំនួនកំណត់ មានតែដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១០នាក់និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៨នាក់ប៉ុណ្ណោះដែលនឹងត្រូវអនុញ្ញាតិឱ្យចូលក្នុងបន្ទប់សវនាការ ។ អាទិភាពនឹងត្រូវផ្ដល់ជូនទៅដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមាននូវអ្នកតំណាងតាមផ្លូវច្បាប់ ។ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត ដែលមានបំណងចូលរួមក្នុងកិច្ចប្រជុំនេះនឹងរៀបចំឱ្យអង្គុយនៅកន្លែងសម្រាប់សាធារណៈជន ។ ពាក់ព័ន្ធនិងចំណុចនេះ ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានបំណងចង់ចូលរួមក្នុងកិច្ចប្រជុំ និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវជូនដំណឹងទៅផ្នែកគ្រប់គ្រងតុលាការឱ្យបានមុនថ្ងៃអង្គារ ទី ១៣ ខែ មករា ឆ្នាំ ២០០៩ ដើម្បីជួយសម្រួលដល់ការរៀបចំកន្លែងអង្គុយ ។

[1] សូមមើលឯកសារ E5/1, E5/3, E5/4

៧. ចំពោះពេលវេលាដែលមាននៅក្នុងរបៀបវារៈគឺគ្រាន់តែជាការចង្អុលបង្ហាញតែប៉ុណ្ណោះ ហើយអង្គជំនុំជម្រះសាលាដំបូងរក្សាសិទ្ធិក្នុងការកែប្រែ ។

## របៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី ១៥ ដល់ ១៦ ខែ មករា ឆ្នាំ ២០០៩

## ១៥ ខែ មករា ឆ្នាំ ២០០៩

**ពេលព្រឹក**

៨.៣០ ចុះឈ្មោះអ្នកចូលរួម

៩.០០ សន្ទរកថាស្វាគមន៍បើកកម្មវិធី ថ្លែងដោយប្រធានអង្គជំនុំជម្រះសាលាដំបូង

- បញ្ហាបឋមៈ ការទទួលស្គាល់មេធាវីអន្តរជាតិ ៖
  - ការស្នើឱ្យទទួលស្គាល់មេធាវីអន្តរជាតិសម្រាប់ ដើមបណ្ដឹងរដ្ឋប្បវេណី (វិធាន ២៣ (៧)(ង)(ក))
  - ការស្នើឱ្យទទួលស្គាល់មេធាវីអន្តរជាតិសម្រាប់ មេធាវីការពារក្ដី (វិធាន ២២ (២) (ក))

១. **ពិនិត្យឡើងវិញអំពីស្ថានភាពទូទៅរបស់ភាគីនីមួយៗនៃកិច្ចដំណើរការនីតិវិធី - ជាមួយផ្នែកគាំពារការការពារក្ដី មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ផ្នែកមន្ទីរឃុំឃាំង និងផ្នែកអង្គភាពជនរងគ្រោះ**

- ស្ថានភាពសុខភាព និងព័ត៌មានដទៃទៀតទាក់ទងនឹងជនជាប់ចោទ
- សមាសភាពរបស់ក្រុមមេធាវីការពារក្ដី

១០.២៥ - ១០.៤៥ សម្រាក

- បច្ចុប្បន្នភាពស្ដីពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងតំណាងផ្លូវច្បាប់របស់ពួកគេ (បទបង្ហាញសង្ខេបរបស់អង្គភាពគាំពារជនរងគ្រោះ និងការពិភាក្សា)
- សមាសភាពរបស់ក្រុមសហព្រះរាជអាជ្ញា

១២.០០ សម្រាក៖បញ្ចប់នូវកម្មវិធីពេលព្រឹក

**ពេលថ្ងៃត្រង់**

១.៣០

២ **បញ្ហាពាក់ព័ន្ធនឹងសាក្សី - ជាមួយផ្នែកគាំពារសាក្សី និងអ្នកជំនាញ WESU និងផ្នែកCMS**

- បញ្ហាពាក់ព័ន្ធវិធានការការពារ និងភស្តុភារសម្រាប់គាំទ្រការធ្វើសក្ខីកម្មរបស់សាក្សីក្នុងពេលសវនាការ (បទបង្ហាញសង្ខេបរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ និងការពិភាក្សា)

២.៣០ - ២.៥០ សម្រាក

- បញ្ហាពាក់ព័ន្ធបញ្ជីឈ្មោះសាក្សី
- គោលការណ៍ណែនាំពីអង្គជំនុំជម្រះសាលាដំបូង ស្តីពីការធ្វើសក្ខីកម្មរបស់សាក្សី (ស្នើឡើងដោយសហព្រះរាជអាជ្ញា )
- តើត្រូវដោះស្រាយជាមួយសាក្សីបន្ថែមយ៉ាងដូម្តេច បើសាក្សីនោះ (មិន) មាននៅក្នុងសំណុំរឿង ប៉ុន្តែ/និង មិនមាននៅក្នុងដីកាដំណោះស្រាយ ហើយសាក្សីបន្ថែមនោះអាចផ្តល់កសិណសាក្សីចំពោះការចោទប្រកាន់បន្ថែមថ្មី ? (ស្នើឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី)
- តើអង្គជំនុំជម្រះសាលាដំបូងមានបំណងកំណត់នូវកាលបរិច្ឆេទ សម្រាប់ការដាក់នូវបញ្ជីឈ្មោះសាក្សីនិងវត្ថុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីថ្មីដែរឬទេ ? ប្រសិនបើកំណត់ តើកំណត់នៅថ្ងៃណា ? (ស្នើឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី)
- ការកំណត់នូវកាលបរិច្ឆេទសវនាការ ដើម្បីស្តាប់នូវដើមបណ្តឹងរដ្ឋប្បវេណីដែលបានជ្រើសរើស (ស្នើឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី)

៤.០០ សម្រាក៖ បញ្ចប់នូវកម្មវិធីពេលថ្ងៃត្រង់

**១៦ ខែ មករា ឆ្នាំ ២០០៩**

**<u>ពេលព្រឹក</u>**

៩.០០

៣ **<u>វិធាននៃភស្តុតាង - អញ្ជើញចូលរួមក្នុងផ្នែកនេះមាន ផ្នែកគ្រប់គ្រងតុលាការCMS</u>**

- នីតិវិធីសម្រាប់ដាក់ភស្តុតាង តាមវិធាន៨៧.២ នៃវិធានផ្ទៃក្នុង
- គោលការណ៍ណែនាំពីអង្គជំនុំជម្រះសាលាដំបូង ស្តីពីការជូនដំណឹងអំពីភស្តុតាង ដែលភាគីមានបំណងសុំឱ្យពិនិត្យ (ស្នើឡើងដោយសហព្រះរាជអាជ្ញា )

៤ **<u>ការគ្រប់គ្រងសវនាការ - អញ្ជើញចូលរួមក្នុងផ្នែកនេះមាន ផ្នែកគ្រប់គ្រងតុលាការCMS</u>**

- បទបញ្ជាសម្រាប់គ្រប់គ្រងសវនាការ
- ការធ្វើប្រតិចារឹកនិងផ្នែកសោតទស្សន៍ (ស្នើឡើងដោយសហព្រះរាជអាជ្ញា) (បទបង្ហាញសង្ខេបរបស់ផ្នែកគ្រប់គ្រងតុលាការ CMS និងការពិភាក្សា)

១០.៣០ - ១០.៥០ សម្រាក

- ការអនុវត្តន៍ការផ្តល់នូវសេវាបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ (បទបង្ហាញសង្ខេបរបស់អង្គភាពបកប្រែភាសា និងការពិភាក្សា)

- ចំនួនម៉ោងជំនុំជម្រះ ចំនួនថ្ងៃជំនុំជម្រះ ថ្ងៃបុណ្យជាតិ ពេលសម្រាករបស់តុលាការ និងការប៉ាន់ប្រមាណរយៈពេលសម្រាប់សវនាការ
- កាលបរិច្ឆេទណាមួយសម្រាប់ការចាប់ផ្តើមការជំនុំជម្រះក្តី និងការកំណត់កាលបរិច្ឆេទសវនាការ

១២.០០ សម្រាក៖បញ្ចប់នូវកម្មវិធីពេលថ្ងៃត្រង់

**<u>ពេលថ្ងៃត្រង់</u>**

១.៣០

**៥ <u>របៀបវារៈបន្ថែមដែលបានស្នើឡើងដោយភាគី - ជាមួយផ្នែកកិច្ចការសាធារណៈ PAS</u>**

- ការផ្សាយសវនាការ និងការគ្រប់គ្រងព័ត៌មាន(ស្នើឡើងដោយសហព្រះរាជអាជ្ញា) (បទបង្ហាញសង្ខេបរបស់ផ្នែកកិច្ចការសាធារណៈ និងការពិភាក្សា)

២.៣០-២.៥០ សម្រាក

- សន្និរកថាបិទកម្មវិធី ថ្លែងដោយប្រធានអង្គជំនុំជម្រះសាលាដំបូង